# បូស្នី-ហឺសេហ្គោវីន (BiH)

## សូចនាករប្រទេស

- **រយៈពេលមានជម្លោះនិងការប្រើប្រាស់គ្រាប់មីន/កាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម:** ការរងគ្រោះថ្នាក់ សំខាន់បណ្តាលមកពីជម្លោះ ១៩៩២-១៩៩៥ ដែលពាក់ព័ន្ធនឹងការបែកបាក់នៃសាធារណរដ្ឋសហភាពសង្គមនិយមយូហ្គូស្លាវី[១] ។
- **ការប៉ាន់ប្រមាណពីការប៉ះពាល់:** ការរងការខូចខាត តាមការប៉ាន់ប្រមាណថា នៅលើផ្ទៃដី ១,៧៣៨ គ.ម[២] ដែលប៉ះពាល់ដល់ប្រជាជនចំនួន ៩២១,៥១៣ នាក់[២] ។
- **សន្ទស្សន៍អភិវឌ្ឍធនធានមនុស្ស :** ស្ថិតចំណាត់ថ្នាក់ទី៦៦ ក្នុងចំណោមប្រទេស ១៧៩, BiH មានការអភិវឌ្ឍធនធានមនុស្សកម្រិតមធ្យម (ធៀបនឹងឆ្នាំ២០០៤ ចំណាត់ថ្នាក់ទី៧៦ ក្នុងចំណោមប្រទេសចំនួន ១៧៧)[៣]
- **ចំណូលជាតិសរុប (តាមវិធីសាស្ត្រ អាទ្លូស) :** មានចំនួន ៤,៥១០ ដុល្លា អាមេរិក—ចំណាត់ថ្នាក់ទី១០៦ក្នុងចំណោមប្រទេស/តំបន់ចំនួន២១០ (ធៀបនឹងឆ្នាំ២០០៤ មានចំនួនត្រឹមតែ ២,៦៩២ ដុល្លាអាមេរិកប៉ុណ្ណោះ)[៤]
- **អត្រាគ្មានការងារធ្វើ:**មាន២៩%(ធៀបនឹងឆ្នាំ២០០៤មានដល់៤០%)[៥]
- **ធនធានខាងក្រៅសម្រាប់ថែទាំសុខភាពគិតជាភាគរយនៃចំណាយសរុប:** ១% (ធៀបនឹងឆ្នាំ២០០៤ មានចំនួន ១.១%)[៦]
- **ចំនួនអ្នកថែទាំសុខភាពអាជីព:** មាន៦១នាក់ក្នុងចំនួនប្រជាជន ១០,០០០នាក់[៧] ។
- **ស្ថានភាពអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ:** មិនមែនជាប្រទេសហត្ថលេខីគិតត្រឹមថ្ងៃទី១ ខែសីហា ឆ្នាំ២០០៩[៨] ។
- **ថវិកាចំណាយលើវិស័យពិការភាព :** អត់មានទិន្នន័យ ។
- **ការវាស់វែងអំពីភាពក្រីក្រ និង ការអភិវឌ្ឍន៍ :** ជម្លោះនៅក្នុងប្រទេស BiH ចន្លោះឆ្នាំ១៩៩២-១៩៩៥ បានធ្វើឱ្យផលិតផលសេដ្ឋកិច្ចធ្លាក់ចុះមកត្រឹម ៨០% និងបណ្តាលឱ្យអត្រាអត់ការងារកើនខ្ពស់ ។ ទោះបីជាស្ថានភាពបានប្រសើឡើងក៏ដោយ ភាពអត់ការងារធ្វើ និងការពឹងផ្អែកលើទំនិញនាំចូល នៅតែមានកម្រិតខ្ពស់ ។ ប្រហែលជាមានប្រជាជន២៥%រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ដែលដូចគ្នានឹងប្រទេស "របបគ្រប់គ្រងអន្តរកាល" ផ្សេងៗទៀត ដែលបណ្តាលឱ្យមានការផាត់ចេញពីសង្គម និង កង្វះលទ្ធភាពទទួលបានបទដ្ឋានរស់នៅសមរម្យ ។ ប្រជាជនមួយផ្នែកមានប្រាក់ចំណូលទាប កង្វះអាហារ និងមានឱកាសការងារតិចតួច ចំណែកមួយចំនួនទៀត ងាយទទួលរងគ្រោះធ្លាក់ចូលទៅក្នុងវដ្តនៃភាពក្រីក្រ[៩] ។

## សេចក្តីសង្ខេបការជួយជនរងគ្រោះក្នុងប្រទេស

| ចំនួនសរុបនៃអ្នករងគ្រោះថ្នាក់ដោយសារមីន/សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ចាប់ពីឆ្នាំ១៩៩២: មិនដឹង- យ៉ាងហោចណាស់មានអ្នកនៅរស់រានជីវិតចំនួន ៧៣០០ នាក់ | | | |
|---|---|---|---|
| ឆ្នាំ | សរុប | ស្លាប់ | របួស |
| ២០០៤ | ២៤ | ១៣ | ១១ |
| ២០០៥ | ២៥ | ១៥ | ១០ |
| ២០០៦ | ៣៥ | ១៨ | ១៧ |
| ២០០៧ | ៣០ | ៨ | ២២ |
| ២០០៨ | ៣៩ | ១៩ | ២០ |
| **សរុប** | **១៥៣** | **៧៣** | **៨០** |

- **ចំនួនប៉ាន់ស្មាននៃអ្នករស់រានពីគ្រាប់មីន /សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម::** គ្មានតួរលេខ ។ ប៉ុន្តែប្រហែលមានចំនួន ៣,៩១៩នាក់[១០] ។
- **ស្ថាប័នសម្របសម្រួល/ក្រុមបង្គោលជំនួយជនរងគ្រោះ:** មជ្ឈមណ្ឌលសកម្មភាពកំចាត់មីន (BiH) ត្រូវបានផ្តល់អាណត្តិដោយទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសម្របសម្រួលជំនួយជនរងគ្រោះ ។ អ្នកជំនាញផ្នែកទិន្នន័យ និងបច្ចេកវិទ្យាព័ត៌មាននៅមជ្ឈមណ្ឌលនេះ ដើរតួនាទីសម្របសម្រួលច្រើនបំផុត គឺច្រើនជាងមន្ត្រីជំនួយសង្គ្រោះ ។ យូរៗម្តងជំនួយការរដ្ឋមន្ត្រីក្រសួងសុខាភិបាល(វេជ្ជបណ្ឌិតផ្នែកវេជ្ជសាស្ត្រ) នៃសហព័ន្ធ (BiH) មកតំណាងឱ្យ BiH នៅឯកិច្ចប្រជុំអន្តរជាតិ ។
- **ផែនការជួយជនរងគ្រោះ :** ផែនការជំនួយជងរងគ្រោះគឺជាយុទ្ធសាស្ត្ររងនៃយុទ្ធសាស្ត្រ សកម្មភាពមីនឆ្នាំ២០០៥-២០០៩ ។ ផែនការនេះនៅមិនទាន់អនុវត្តនៅឡើយទេ ។ ចន្លោះឆ្នាំ ២០០៩-២០១៩ ការព្រមព្រៀង ត្រូវរងចាំរហូតដល់មានយុទ្ធសាស្ត្ររងថ្មីមួយទៀត ។
- **សាវតារជំនួយជនរងគ្រោះ :** ចន្លោះឆ្នាំ១៩៩៥-២០០៤ សេវាកម្មជំនួយជនរងគ្រោះដោយផ្ទាល់ ភាគច្រើនត្រូវបានផ្តល់អោយដោយអង្គការអន្តរជាតិ ដែលបណ្តាលឱ្យមានការផ្តល់សេវាកម្មមិនមានលក្ខណៈជាប្រព័ន្ធ ។ នៅពេលដែលថវិកាក្រោយជម្លោះសម្រាប់កិច្ច ប្រឹងប្រែងរបស់អង្គការចាប់ផ្តើមធ្លាក់ចុះបន្ទាប់ពីឆ្នាំ២០០៤ សមត្ថភាពអន្តរជាតិ សម្រាប់ជំនួយជនរងគ្រោះក៏ធ្លាក់ចុះផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ ក៏កិច្ចប្រឹងប្រែងជំនួយជនរងគ្រោះបានបន្តពឹងផ្អែកជាសំខាន់ទៅលើការចូលរួមចំណែកពីអន្តរជាតិ ចន្លោះឆ្នាំ២០០៥-២០០៩ ។ បទបញ្ញត្តិ និងផលប្រយោជន៍សម្រាប់ជនពិការខុសប្លែកគ្នាពីក្នុងចំណោមអង្គភាព[១១] និងរវាងតំបន់ផ្សេងៗប៉ុន្តែសេវាកម្ម

ដែលគ្រប់គ្រងដោយរដ្ឋភាគច្រើន ធ្វើឡើងដោយមិនគិតថ្លៃចំពោះក្រុមខ្លះ ដោយរួមបញ្ចូលយោធិនពិការ និង ប្រជាជនដែលមានការធានារ៉ាប់រង។ ជាទូទៅសេវាកម្មសម្រាប់យោធិនពិការ និងប្រាក់សោធន មានលក្ខណៈល្អប្រសើរជាងសេវាកម្ម និងប្រាក់សោធនមន្ត្រីស៊ីវិល។ ក្នុងឆ្នាំ២០០៩ ទាំងការស្តារកាយសម្បទានិងការគាំពារផ្នែកវេជ្ជសាស្ត្រត្រូវបានគិតថាសមស្របតាមតម្រូវការ។ ជំនួយផ្នែកវេជ្ជសាស្ត្រ មានលក្ខណៈសមស្របតាំងពីឆ្នាំ២០០៤ ទោះបីជាមានការពឹងអាស្រ័យជំនួយអន្តរជាតិដោយសារជម្លោះ។ ភាពរីកចំរើនបានកើតមានជាពិសេសចំពោះសេវាកម្មឆ្លើយតបនឹងបញ្ហាសង្គ្រោះបន្ទាន់ ដោយសារការចូលរួមចំណែកពីម្ចាស់ជំនួយអន្តរជាតិ។ សេវាកម្មស្តារកាយសម្បទា នៅតែមិនស្ថិតស្ថេរនៅក្នុងឆ្នាំ២០០៩ ប៉ុន្តែជារួមគុណភាពរបស់វាមានលក្ខណៈគួរឱ្យពេញចិត្ត ទោះបីជាកង្វះខាតបុគ្គលិកដែលទទួលការបណ្តុះបណ្តាលតាមបទដ្ឋានអន្តរជាតិ ក្រុមការងារស្តារលទ្ធភាពពលកម្មមិនពេញលេញ និងការិយាធិបតេយ្យដ៏ស្មុគស្មាញក៏ដោយ។ សមត្ថភាពរបស់រដ្ឋាភិបាល ដើម្បីផ្តល់ហិរញ្ញបទានដល់សេវាស្តារលទ្ធភាពពលកម្ម មានភាពប្រសើរឡើងចាប់តាំង ពីឆ្នាំ ២០០៤។ មណ្ឌលសង្គមដែលគ្រប់គ្រងដោយរដ្ឋ និងបណ្តាញមណ្ឌលស្តារកាយសម្បទាផ្អែកលើសហគមន៍ដែលបង្កើតនៅឆ្នាំ១៩៩៨ ផ្តល់ការគាំទ្រផ្នែកចិត្តសង្គម ប៉ុន្តែនៅតែទទួលរងពី ការខ្វះខាតសមត្ថភាព និងចំណេះដឹងអំឡុងឆ្នាំ២០០៥-២០០៩។ អង្គការមិនមែនរដ្ឋាភិបាល ក៏បានជួយគាំទ្រប្រភេទនេះផងដែរ។ កំឡុងពេលនេះ ការខ្វះចន្លោះឥតដាច់ក្នុងការរួមបញ្ចូលផ្នែកសេដ្ឋកិច្ចនៅតែកើតមាន ដែលមួយផ្នែកដោយសារអត្រាអត់ការងារធ្វើមានកម្រិតខ្ពស់ពេក។ សកម្មភាពទាក់ទងការរួមបញ្ចូលផ្នែកសេដ្ឋកិច្ចស្ទើរតែទាំងអស់ ត្រូវបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែចន្លោះឆ្នាំ២០០៧-២០០៨ សកម្មភាពបែបនេះមួយបានទទួលថវិកាសហការពីអង្គភាពមួយ។ ច្បាប់ស្តីពីពិការភាពពិតជាមាន ប៉ុន្តែមិនបានអនុវត្តឱ្យបានត្រឹមត្រូវ។ លើសពីនេះទៀតនោះ វិសមភាពនៃលទ្ធភាពនិងការខ្វះចន្លោះរវាងសេវាកម្ម នៅជនបទនិងទីប្រជុំជនបានកើនឡើង។ ចាប់ពីឆ្នាំ២០០៥-២០០៩ ទិន្នន័យស្តីពីអ្នកនៅរស់រានមានជីវិតនិងជនរងគ្រោះ នៅតែមិនពេញលេញ និងមិនអាចប្រើប្រាស់បានសម្រា ប់ធ្វើផែនការជំនួយជនរងគ្រោះ។

## ភាពជឿនលឿនពីជំនួយជនរងគ្រោះនៅមូលដ្ឋាន

### *សាវតារអ្នកផ្តល់ចំលើយ*

សម្រាប់ BiH ចម្លើយចំនួន៤៦ ត្រូវបានទទួលត្រឹមខែកក្កដា ឆ្នាំ២០០៩ : ៤៤ នាក់ (៩៦%) គឺជាបុរស និង២នាក់ជាស្ត្រី។ អ្នកទាំងអស់នោះ មានអាយុចន្លោះពី២៦-៧៨ឆ្នាំ និងមាន៧៨%ដែលមានអាយុចន្លោះពី៣៥-៤៩ឆ្នាំ។ ក្រុមអ្នកផ្តល់ចម្លើយធំបំផុត (៤៣%) រស់នៅតាមភូមិ ដែលទទួលបានសេវាកម្មមួយចំនួន ដែលតាមពីក្រោយដោយប្រជាជនដែលរស់នៅតាមទីក្រុងធំៗ ដែលទទួលបានសេវាកម្មគ្រប់ប្រភេទ (៣០%) ប្រជាជនដែលរស់នៅតំបន់ដាច់ស្រយាល ដែលមិនទទួលបានសេវាកម្មសោះ (១៣%) និងប្រជាជនមកពីរាជធានី (៧%)[១២]។ ប្រហែលជាអ្នកផ្តល់ចម្លើយ៧២% យ៉ាងហោចណាស់បានបញ្ចប់ការសិក្សានៅអនុវិទ្យាល័យ។ ប្រហែលជាមាន ៨៩% ជាមេគ្រួសារ និង៧២%គ្រប់គ្រងកម្មសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេ។ ប្រហែលជាមានអ្នកផ្តល់ចម្លើយពាក់កណ្តាល (៤៨%) អត់មានការងារធ្វើអំឡុងពេលចុះស្ទង់មតិ ទោះបីជា៨៦%នៃពួកគេមានការងារធ្វើមុនជួបឧប្បត្តិហេតុ (ពួកគេភាគច្រើន ត្រូវបានកែនធ្វើជាកងទ័ពដើម្បីទប់ទល់នឹងជម្លោះ ដែលជាពេលវេលាមានឧប្បត្តិហេតុ ប៉ុន្តែប្រហែលជាបានបន្សល់ទុកការងារបំរើទ័ពចោល)។ ភាគច្រើនលើសលុប (៨៩%) យល់ឃើញថា ប្រាក់ចំណូលគ្រួសាររបស់ពួកគេមិនគ្រប់គ្រាន់។ ជាង៣/៤នៃអ្នកផ្តល់ចម្លើយ (៧៨%) គឺជាទាហ៊ាននៅពេលដែលមានឧប្បត្តិហេតុ។ ឧប្បត្តិហេតុភាគច្រើន កើតឡើងអំឡុងពេល ឬភ្លាមបន្ទាប់ពីជម្លោះ (៩១%)។ ចំនុចនេះត្រូវគ្នាជាមួយទិន្នន័យពិបាករកស្តីពីជនរងគ្រោះ ដែលគូសបញ្ជាក់ថា ប្រហែលជា៨៨%នៃជនរងគ្រោះ កើតមានក្នុងអំឡុងពេលមានជម្លោះនិងភ្លាមៗបន្ទាប់ពីជម្លោះ (១៩៩២-១៩៩៦) ហើយថាជនរងគ្រោះភាគច្រើនគឺជាបុរសដែលជាកងកំលាំងប្រដាប់អាវុធ[១៣]។

### ជំនួយបានមកពីអ្នកផ្តល់ជំនួយផ្សេងៗគ្នា




## *ការរកឃើញទូទៅ*[១៤]

អ្នកផ្តល់ចម្លើយភាគច្រើន មានអារម្មណ៍ថា ជារួមសេវាកម្មនៅតែដដែលចាប់តាំងពីឆ្នាំ២០០៥ ៧០%មិនមានអារម្មណ៍ថាពួកគេបានទទួលសេវាកម្មច្រើនជាងកាលពីឆ្នាំ២០០៥ និង៧៤%ទៀតគិតថា សេវាកម្មទាំងនោះមិនមានភាពប្រសើរជាងមុននោះទេ។ អ្នក ផ្តល់ចម្លើយមកពីជនបទដែលសេវាកម្មនៅទីនោះត្រូវការជា ចាំបាច់បានរាយការណ៍ថា មានភាពរីកចំរើនតិចជាងនៅតំបន់ ទីប្រជុំជន។ អ្នកផ្តល់ចម្លើយជាស្ត្រីពីររូបបានរាយការណ៍ថា ស្ថានភាពមានសភាព "អាក្រក់ជាងមុន" ឬ "អាក្រក់ជាងមុន ឆ្ងាយណាស់" សម្រាប់ស្ត្រី ចំណែក៥២% បានអះអាងថាសេវាកម្មសម្រាប់អ្នកនៅរស់រានមានជីវិតជាស្ត្រី មានសភាពអាក្រក់ជាងមុនឬអត់មានទាំងស្រុង។ ប្រជាជនភាគច្រើន (៥៩%) មិនបានដឹងថាតើសេវាកម្ម សម្រាប់អ្នកនៅរស់រាន មានជីវិតជាកុមារ ត្រូវរៀបចំឱ្យត្រូវទៅតាមអាយុរបស់ពួកគេ ប៉ុន្តែ២៦%មានអារម្មណ៍ថា នេះគឺ "ស្ទើរតែមិនមែន" ជាការពិត ៤%ទៀតជឿថាវាគឺ "មិនមែន" ជាការពិតតែម្តង និង១១%ទៀតជឿថា វាជាការពិត "ដោយអន្លើ"។ ចម្លើយនេះប្រហែលជាឆ្លុះបញ្ចាំងពីការធ្លាក់ចុះជាបណ្តើរៗនៃជនរងគ្រោះជាកុមារចាប់តាំងពី ឆ្នាំ២០០៤[១៥]។

អ្នកផ្តល់ចម្លើយភាគច្រើន (៧៦%) ស្ទង់មតិដោយអាជ្ញាធរ ឬអង្គការមិនមែនរដ្ឋាភិបាលជាងបីដងតាំងពីឆ្នាំ២០០៥ ប៉ុន្តែ១១%ទៀតមិនធ្លាប់ទទួលបានការស្ទង់មតិឡើយ។ មតិភាគច្រើនក្នុងចំណោមអ្នកផ្តល់ចម្លើយ (៦៥%) បាននិយាយថា ការចូលរួមបានធ្វើឱ្យព័ត៌មានកើនឡើងទាក់ទងនឹងសេវាកម្ម ប៉ុន្តែ៣៩%និយាយថា ពួកគេបានទទួលសេវាកម្មច្រើនជាងមុន ៦៥%និយាយថាមានឱកាសពន្យល់ពីតម្រូវការរបស់ពួកគេដល់តំណាងរដ្ឋាភិបាល ដោយមាន៣៧%ដែលបានធ្វើដូច្នេះបួនដង ឬច្រើនជាងនេះ។

### និន្នាការនៃសេវាជួយរងគ្រោះចាប់ពីឆ្នាំ២០០៥




## ***សង្គ្រោះបន្ទាន់និងការថែទាំបន្តផ្នែកវេជ្ជសាស្ត្រ***

អ្នកផ្តល់ម្លើយជាច្រើននិយាយថា ជារួមសេវាកម្មគាំពារសុខភាព ស្ថិតនៅដដែល (៥០%) ឬប្រសើឡើង (៣៩%) ចាប់តាំងពីឆ្នាំ២០០៥ ១១% និយាយថា ស្ថានភាពនេះបានក្លាយទៅជាអាក្រក់ជាងមុន។ ភាគច្រើន (៦៣%) ជឿជាក់ថា អ្នកនៅរស់រានមានជីវិត ពេលខ្លះប៉ុណ្ណោះដែលទទួលបានការគាំពារសុខភាពតាមតម្រូវការរបស់ពួកគេ ប៉ុន្តែ១៥%និយាយថា "ស្ទើរតែមិនដែលសោះ"។ អ្នកផ្តល់ចម្លើយជាច្រើនមើលឃើញពីការរីកចំរើនបំផុតនៅត្រង់លទ្ធភាពទទួលបានថ្នាំលេប (៦៧%) សេវាកម្មដឹកជញ្ជូនសង្គ្រោះបន្ទាន់កើនឡើង (៦៣%) សម្ភារៈផ្គត់ផ្គង់ និងគ្រឿងបរិក្ខាផ្សេងៗបានល្អជាងមុន (៦៣%) កើនឡើងនូវភាពអាចលៃលកបាន (៦១%) និងមានការពឹងផ្អែកស្រួលជាងមុនចំពោះសេវាកម្ម ឯកទេស ឬតាមដានផ្សេងៗ (៦១%)។ ភាពរីកចំរើនតិចតួចបំផុត ត្រូវបានកត់សំគាល់ឃើញចំពោះលទ្ធភាពទទួលបានសេវាកម្មនៅជិតផ្ទះ (៣៩%) និងចំនួនមណ្ឌលសុខភាព (៣៧%) -ភាគច្រើននៃអ្នកដែលមើលឃើញពីភាពរីកចំរើនក្នុងវិស័យនេះ រស់នៅតាមទីក្រុងធំៗ ឬរាជធានី។ ស្រដៀងគ្នានេះដែរ អ្នកផ្តល់ចម្លើយចំនួន៣៩% បាននិយាយថា បុគ្គលិកសុខាភិបាល បានទទួលការបណ្តុះបណ្តាលល្អជាងមុន ឬបានមើលឃើញការធ្វើឱ្យប្រសើឡើងដល់គុណភាពនៃការគាំពារសុខភាព។ ជិត២៥%បាននិយាយថា រដ្ឋាភិបាលបានផ្តល់ការគាំទ្រច្រើនជាងមុនដល់ការគាំពារសុខភាព (២៤%)។

BiH បាយរាយការណ៍ថា ចាប់តាំងពីឆ្នាំ២០០៥ ប្រទេសនេះមានបណ្តាញគាំពារសុខភាពល្អជាងមុន ដោយមិនគិតថ្លៃចំពោះជនណា ដែលមានការធារ៉ាប់រងជីវិត ឬលក្ខខ័ណ្ឌផ្សេងៗដែលគំរាមដល់អាយុជីវិត បុគ្គលិកដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និងគ្រឿងបំពាក់សមស្រប។ ទាំងនេះអាចជួយពន្យល់បានពីមូលហេតុដែលអ្នកនៅរស់រានមានជីវិតមិនបានកត់សំគាល់ឃើញពីភាពរីកចំរើនដ៏មហិមា (ទោះបីជាមនុស្សជាច្រើននៅតែខ្វះខាតការធានារ៉ាប់រងផ្នែកសុខភាពក៏ដោយ)។ ពីព្រោះអ្នកផ្តល់ចម្លើយជាច្រើនគឺជាយោធា ពួកគេបានទទួលប្រយោជន៍ពីការធានារ៉ាប់រងដោយស្វ័យប្រវត្តិ។ សេវាកម្មសំខាន់ៗដែលគេត្រូវការជាចាំបាច់នោះ គឺសេវាដឹកជញ្ជូនលក្ខណៈសង្គ្រោះបន្ទាន់ និងការអន្តរាគមន៍ផ្នែកវេជ្ជសាស្ត្រលក្ខណៈសង្គ្រោះបន្ទាន់។ ទាំងពីរនេះ ត្រូវបានធ្វើឱ្យប្រសើឡើងនៅក្នុងឆ្នាំ២០០៦ ដោយមានការគាំទ្រហិរញ្ញវត្ថុពីអន្តរជាតិទៅលើសកម្មភាពមួយចំនួន ដែលមិនពាក់ព័ន្ធនឹងការធ្វើផែនការជំនួយជនរងគ្រោះ[១៦]។

## *ការស្តារនីតិសម្បទា*

អ្នកផ្តល់ចម្លើយប្រហែល ៣៥% កត់សំគាល់ឃើញថាមានភាពប្រសើរឡើងផ្នែកស្តារកាយសម្បទាចាប់តាំងពីឆ្នាំ២០០៥ ៤៨%កត់សំគាល់ថាមិនមានភាពប្រែប្រួល និង១៥%ទៀតគិតថាស្ថានភាពនេះបានធ្លាក់ចុះ[១៧]។ ទោះបីជាយ៉ាងណាក៏ដោយ តម្រូវការរបស់អ្នកនៅរស់រានមានជីវិតទំនងជាមិនត្រូវបានបំពេញ ដោយ៤១%នៃអ្នកផ្តល់ចម្លើយនិយាយថា អ្នកនៅរស់រានមានជីវិត "មានពេលខ្លះប៉ុណ្ណោះ" ដែលទទួលបានសេវាស្តារកាយសម្បទាតាមតម្រូវការរបស់ពួកគេ និង១៧%និយាយថា ចំនុចនេះ "ស្ទើរតែមិនមែន" ជាការពិត (៩% "ភាគច្រើន" ៤% "ជានិច្ច" និង២៦% "មិនច្បាស់")។ ប្រមាណ៤%ជឿជាក់ថា តម្រូវការស្តារកាយសម្បទារបស់អ្នកនៅរស់រានមានជីវិត តែងត្រូវបានបំពេញជានិច្ច។ ចំនុចដែលមានការរីកចំរើនបំផុតគឺ : គុណភាពឧបករណ៍ (៥៤%) និងការកើនឡើងសេវាស្តារកាយសម្បទានៅតាមមន្ទីរពេទ្យភ្លាម បន្ទាប់ពីអន្តរាគមន៍ផ្នែកវេជ្ជសាស្ត្រ (៥០%)។ ប្រហែលជាមិនដល់ពាក់កណ្តាលក្នុងចំណោមអ្នកផ្តល់ចម្លើយទាំងអស់បានរាយការណ៍ថា ក្រុមស្តារលទ្ធភាពពលកម្ម មានលក្ខណៈពេញលេញ និងមានប្រភេទឧបករណ៍ទ្រទ្រង់រាយកាយសប្បនិម្មិត និងប្រភេទឧបករណ៍ទំនើប៧ផ្សេង៧ជាច្រើនទៀតអាចលៃលករកបាន (៤៨%)។ ជារួម ចម្លើយតបទាំងឡាយគូសបញ្ជាក់ពីវិឌ្ឍនភាពកម្រិតមធ្យម ពិសេសទាក់ទងនឹងគុណភាពព្យាបាលរូបរាងកាយ (៤៦%) ការបណ្តុះបណ្តាលបុគ្គលិក (៤៣%) ការស្តាបនា (៤៣%) និងការបង្កលក្ខណៈងាយស្រួលផ្នែករូបវ័ន្ត (៤១%)។ មានតែ២០%ប៉ុណ្ណោះជឿថា រដ្ឋាភិបាលបានផ្តល់ការគាំទ្រច្រើនជាងមុនចំពោះការស្តារកាយសម្បទា។

ក្នុងឆ្នាំ២០០៥ BiH បានប្រកាសថា សេវាស្តារលទ្ធភាពពលកម្មអាចបំរើប្រជាពលរដ្ឋបាន និងចំនួនសាលផលិតឧបករណ៍ទ្រទ្រង់រាងកាយសប្បនិម្មិត និងរណប មានគ្រប់គ្រាន់ដែលឆ្លើយតបតាមតម្រូវការរបស់ប្រទេស។ វាក៏បានរាយការណ៍ផងដែរពីចំនួនដ៏គ្រប់គ្រាន់នៃបុគ្គលិក ដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវ។[១៨] BiH បាននិយាយឡើងវិញពីសេចក្តីថ្លែងការណ៍របស់ខ្លួនថា គុណភាព និងបទដ្ឋាននៃឧបករណ៍ទ្រទ្រង់រាងកាយសប្បនិម្មិត មានសមល្មមសម្រាប់ឆ្នាំ២០០៦ និង២០០៧។[១៩] ទោះជាយ៉ាងនេះក្តី ការស្ទង់មតិរបស់អង្គការមិនមែនរដ្ឋាភិបាល ទៅលើអ្នកនៅរស់រានមានជីវិតចំនួន៥០០នាក់ បានរកឃើញថា គុណភាពនៃសេវាមិនស្ថិតស្ថេរ ក្រុមជាច្រើនមិនមានលក្ខណៈពេញលេញ និងមានការខ្វះខាតបទដ្ឋានភាវូបនីយកម្ម និងការគ្រប់គ្រងគុណភាពឧបករណ៍និងសេវាកម្ម។[២០] ចម្លើយរបស់អ្នកនៅរស់រានមានជីវិត គូសបញ្ជាក់ថា បញ្ហាដូចគ្នាដែលពាក់ព័ន្ធនឹងគុណភាព និងបុគ្គលិកនៅតែបន្តកើតមាន។ ពិសេសជាងនេះទៀត ការប៉ាន់ប្រមាណទូទៅរបស់ពួកគេ ទំនងជាគូសបញ្ជាក់ថា សេវាកម្មជាច្រើនមិនបានឆ្លើយតបតាមគោលបំណងស្តារកាយសម្បទាចន្លោះឆ្នាំ២០០៥-២០០៩របស់ BiH ដើម្បីធានាថា "អ្នកនៅរស់រានមានជីវិតពីគ្រាប់មីនគ្រប់រូប" នឹងទទួលបាននូវ "ឧបករណ៍ទ្រទ្រង់រាងកាយដែលមានគុណភាព និងសេវាស្តារលទ្ធភាពពលកម្មប្រសិនបើចាំបាច់"។[២១] បុគ្គលិកផ្នែកឧបករណ៍ទ្រទ្រង់រាងកាយ និងរណបភាគច្រើននៅក្នុង BiH មិនទទួលបានការបណ្តុះបណ្តាលតាមបទដ្ឋានអន្តរជាតិឡើយក្នុងឆ្នាំ ២០០៩។

## *ការគាំទ្រផ្លូវចិត្ត និង សមាហរណកម្មសង្គម*

អ្នកផ្តល់ចម្លើយ (៦១%) បានចាត់ទុកការគាំទ្រផ្នែកចិត្តសាស្ត្រ និងសេវាកម្មដាក់បញ្ចូលទៅក្នុងសង្គមឡើងវិញ ថាមិនមានភាពប្រែប្រួលចាប់តាំងពីឆ្នាំ២០០៥ ២៨%បានមើលឃើញពីភាពរីកចំរើន និង១១%ទៀតជឿថា ស្ថានភាពនេះបានធ្លាក់អន់ថយ។ ប្រហែល៤១%បានបន្ថែមថា អ្នកនៅរស់រានមានជីវិតមាន "ពេលខ្លះប៉ុណ្ណោះ" ដែលទទួលបានការគាំទ្រផ្នែកចិត្តសង្គមតាមតម្រូវការ ៣៥%ទៀតនិយាយថា តម្រូវការទាំងនេះ "មិនដែល" ឬ "ស្ទើរតែមិនដែល" ទទួលបាន បើប្រៀបធៀបជាមួយ ១៧%ផ្សេងទៀត ដែលឆ្លើយថា អ្នកនៅរស់រានមានជីវិត "ភាគច្រើន" បានទទួលសេវាតាមតម្រូវការ។[២២] ខណៈពេលដែលអ្នកផ្តល់ចម្លើយ (៦៣%) មានអារម្មណ៍ថា មានសិទ្ធិអំណាចច្រើនជាងមុន ៦១%ទៀតគិតថា មិនមានភាពប្រសើរឡើងសម្រាប់អ្នកនៅរស់រានមានជីវិត ដែលត្រូវបានចាត់ទុកថាជា "ករណីសប្បុរសធម៌"។ ឧបសគ្គពាក់ព័ន្ធការស្វែងរកប្រឹក្សាយោបល់លក្ខណៈចិត្តសាស្ត្រ នៅតែកើតមាន ដោយ៣៣%កត់សំគាល់ឃើញថាមានភាពរីកចំរើន ៣៥%និយាយថាវាមានភាពងាយស្រួលជាងមុនក្នុងការទទួលបានប្រឹក្សាយោបល់ជាលក្ខណៈផ្លូវការ និង៣៥%ផ្សេងទៀត និយាយថាមានក្រុមគាំទ្រអ្នកដែលមានអាយុប្រហាក់ប្រហែលគ្នា

ច្រើនជាងមុន។ ជិតពាក់កណ្តាលក្នុងចំណោមអ្នកផ្តល់ចម្លើយនិយាយថា គុណភាពសេវាកម្មបានប្រសើរឡើង (៣៩%) ឬសេវាកម្មនោះ បានកើនឡើង (៣៧%)។ នៅខាងផ្នែកវេជ្ជមាន ៥០% មានអារម្មណ៍ថា បានចូលរួមក្នុងសកម្មភាពសហគមន៍ និង៤៨%រាយការណ៍ថា ពួកគេបានជាប់ពាក់ព័ន្ធច្រើនជាងមុន ក្នុងការងារគាំទ្រផ្នែកចិត្តសង្គមដល់ អ្នកនៅរស់រានមានជីវិតផ្សេងៗទៀត។ ១៣%នៃអ្នកផ្តល់ចម្លើយ និយាយថា រដ្ឋាភិបាលបានបង្កើនការចូលរួមចំណែករបស់ខ្លួនក្នុងការ គាំទ្រផ្នែកចិត្តសង្គម។

ចម្លើយទាំងនេះ ទំនងជាខុសពីរបាយការណ៍ BiH ក្នុង ឆ្នាំ២០០៥ ដែលអ្នកនៅរស់រានមានជីវិតពីគ្រាប់មីនទាំងអស់មាន លទ្ធភាពទទួលបានសេវាពីគ្រឿងបរិក្ខាផ្នែកសុខភាពស្មារតី ដែលអាចជួយដល់បញ្ហាស្លុតបាក់ស្មារតី។ ជាការពិត ការគាំទ្រផ្នែកចិត្តសង្គម តាមរយៈមណ្ឌលស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍ និងសង្គមបានបើកបំរើសេវាចាប់តាំងពីឆ្នាំ១៩៩៨[២៣] ចំណែកការគាំទ្រអ្នកដែលមានអាយុប្រហាក់ប្រហែលគ្នាតាមរយៈអង្គការមិនមែនរដ្ឋាភិបាលត្រូវបានបង្កើតបានយ៉ាងល្អផងដែរមុនឆ្នាំ២០០៤។[២៤] ការពិតដែលថាប្រព័ន្ធទាំងនេះ ត្រូវបានដាក់ឱ្យចំកន្លែងក្នុងរយៈពេលមួយប្រហែលជាអាច ចូលរួមចំណែកដល់ការខ្វះខាតភាពរីកចំរើនដែលបានដឹងរបស់អ្នកផ្តល់ចម្លើយ។ ទោះជាយ៉ាងណាក៏ដោយ មានរបាយការណ៍ជាច្រើន ដែលលាតត្រដាងថាមជ្ឈមណ្ឌលគ្រប់គ្រងដោយរដ្ឋខ្វះសមត្ថភាពនិងថវិកា ហើយថាមានការខ្វះការយល់ដឹងអំពីបញ្ហានេះផងដែរ។ នៅក្នុងឆ្នាំ ២០០៧ BiH បានអះអាងថា ទោះបីជាមជ្ឈមណ្ឌលជំនួយសង្គមមួយចំនួន ជាទ្រើស្តីអាចផ្តល់ការគាំទ្របំពេញចិត្តដល់អ្នកនៅរស់រានមានជីវិតក៏ដោយក៏សមត្ថភាពរបស់ពួកគេ នៅតែមានដែនកំណត់ដោយសារតែការរឹតបណ្តឹងផ្នែកសេដ្ឋកិច្ច។[២៥]

**បំពេញតំរូវការរបស់ជនងាយគ្រោះឆ្នាំ២០០៥**




## *សមាហរណកម្មសេដ្ឋកិច្ច*

អ្នកផ្តល់ចម្លើយភាគច្រើនរាយការណ៍ថា ឱកាសបញ្ចូលផ្នែកសេដ្ឋកិច្ចដល់អ្នកនៅរស់រានមានជីវិត ស្ថិតនៅដដែល (៥២%) ឬធ្លាក់ចុះ (៣៧%) ចាប់តាំងពីឆ្នាំ២០០៥។ ជាង៤៣%បន្ថែមថា អ្នកនៅរស់រានមានជីវិត "មិនដែល" ឬ "ស្ទើរតែមិនដែល" បានទទួលសេវាកម្មដែលមានបញ្ចូលផ្នែកសេដ្ឋកិច្ច ហើយ៣៣%យល់ឃើញថា បញ្ហានេះ "ពេលខ្លះ" ជាការពិត។ ប្រមាណតែ២%ប៉ុណ្ណោះជឿថា អ្នកនៅរស់រានមានជីវិត "តែងតែជានិច្ច" ទទួលបានជំនួយដែលមានបញ្ចូលផ្នែកសេដ្ឋកិច្ច (២២%មិនដឹង)។ ដែលគួរឱ្យបារម្ភ អ្នកផ្តល់ចម្លើយទាំងអស់លើកលែងតែម្នាក់ជឿថាការអត់មានការងារធ្វើ មានកម្រិតខ្ពស់ពេករហូតដល់អ្នកនៅរស់រានមានជីវិត ជាមនុស្សចុងក្រោយដែលត្រូវជ្រើសរើសឱ្យចូលបំរើការងារ។

ជិត៤០% បានមើលឃើញថាមានភាពប្រសើរឡើងនៅក្នុងសូចនាករវាស់វែងពីវឌ្ឍនភាពសេដ្ឋកិច្ច។ ចំនុចនៃវឌ្ឍនភាពដ៏ខ្លាំងបំផុត ត្រូវបានកត់សំគាល់ចំពោះផ្នែកការបង្កលក្ខណៈងាយស្រួលផ្នែករូបវ័ន្ត (៣៩%) ថាមានស្ថានភាពល្អជាងមុន មានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំដែលអាចលៃលកបានច្រើនជាងមុន (៣៥%) និងការថយចុះបញ្ហាការរើសអើង (៣៥%)។ ទោះជាយ៉ាងនេះក្តី មានតែ១៥%ប៉ុណ្ណោះនិយាយថា កម្មវិធីបណ្តុះបណ្តាលការងារ ឆ្លើយតបតាមតម្រូវការទីផ្សារ និងចំនួនមនុស្សដដែលនិយាយថា ពួកគេមានលទ្ធភាពទទួលបានសេវាកម្មប្រសើរជាងមុនដែលមិនជាក់លាក់ចំពោះអ្នកនៅរស់រានមានជីវិត។ ប្រមាណ១៣%គិតថាមានសេវាកម្មរកការងារច្រើនជាងមុន ឬថាកូដតាការងារសម្រាប់ជនពិការត្រូវបានអនុវត្តប្រសើរជាងមុន។ ជិត១/១០ក្នុងចំណោមអ្នកផ្តល់ចម្លើយចាត់ទុករដ្ឋាភិបាលថាបានផ្តល់ការគាំទ្រច្រើនជាងមុនចំពោះសកម្មភាព ដែលមានរួមបញ្ចូលផ្នែកសេដ្ឋកិច្ច (៩%)។

កិច្ចខិតខំប្រឹងប្រែងដ៏តិចតួច (ឬគ្មាន) របស់រដ្ឋាភិបាលចំពោះការបញ្ចូលផ្នែកសេដ្ឋកិច្ចសម្រាប់អ្នកនៅរស់រានមានជីវិត ត្រូវបានរាយការណ៍នៅក្នុងកម្រិតរដ្ឋបាលនៅក្នុង BiH ទោះបីជា BiH ទទួលស្គាល់ថា ការអត់មានការងារធ្វើគឺជាបញ្ហាមួយក្នុងចំណោមបញ្ហាដ៏ធំបំផុតរបស់ប្រទេសយ៉ាងណាក៏ដោយ។ សេវាកម្ម និងកូដតារបស់រដ្ឋមាន ប៉ុន្តែអនុវត្តមិនបានត្រឹមត្រូវ និងមិនកំណត់គោលដៅចំពោះអ្នកនៅរស់រាន មានជីវិតដែលអាស្រ័យហេតុនេះធ្វើឱ្យពួកគេមានការលំបាកក្នុងការទទួលបានការងារ។ ទោះបីជាត្រូវបានកំណត់ថាជាអាទិភាពនៅក្នុងឆ្នាំ២០០៥ ក៏ដោយ BiH មិនបានរាយការណ៍អំពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការសម្របសម្រួលវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបញ្ចូលផ្នែកសេដ្ឋកិច្ចសម្រាប់អ្នកនៅរស់រានមានជីវិត ឬជនពិការរហូតដល់ឆ្នាំ២០០៨ ដែលនៅពេលនោះ ថវិការួមត្រូវបានរៀបចំពីអង្គភាពមួយសម្រាប់គំរោងរបស់អង្គការមិនមែនរដ្ឋាភិបាលមួយ[២៦]។ អង្គការមិនមែនរដ្ឋាភិបាល គឺជាអ្នកផ្តល់សេវាកម្មដ៏មានសារៈសំខាន់ ប៉ុន្តែសកម្មភាពរបស់ពួកគេ នៅមានកម្រិតតូច និងពឹងផ្អែកទៅលើតំលៃប្រែប្រួលនៃថវិកា។ បន្ថែមពីនេះ អង្គការមិនមែនរដ្ឋាភិបាល ទំនងជាបានផ្តោតខ្លាំងទៅលើការគាំទ្រសកម្មភាពចិត្តសង្គម និងការស្តារកាយសម្បទា។

## ***ច្បាប់ និងគោលនយោបាយសាធារណៈ***

អ្នកផ្តល់ចម្លើយប្រហែលជិត ១/៤ (២៤%) គូសបញ្ជាក់ពីភាពប្រសើរឡើងចំពោះស្ថានភាពសិទ្ធិរបស់អ្នកនៅរស់រានមានជីវិត នៅក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ ៤១%បានរាយការណ៍ថាមិនមានភាពផ្លាស់ប្តូរ និង៣០%និយាយថា ស្ថានភាពមានសភាពអាក្រក់ជាងមុន។[២៧] អ្នកផ្តល់ចម្លើយ ជាងពាក់កណ្តាល (៥២%) ជឿជាក់ថាសិទ្ធិរបស់អ្នកនៅរស់រានមានជីវិត គឺមាន "ពេលខ្លះ" ត្រូវបានគេគោរព ២៩%និយាយថា "ស្ទើរតែមិន" ១៥%ទៀតនិយាយថា "ភាគច្រើន" និង៤%ទៀតមិនដឹង។ អ្នកនៅរស់រានមានជីវិតជាច្រើន បានរាយការណ៍ពីវឌ្ឍនភាពដ៏ខ្លាំងក្លាបំផុតក្នុងការទទួលបានការដោះស្រាយលើការរំលោភសិទ្ធិរបស់ពួកគេតាមផ្លូវច្បាប់ (៥០%) ក៏ដូចជាការកើនឡើងនូវព័ត៌មានអំពីសិទ្ធិ (៤៦%) និងអំពីសេវាជំនួយជនរងគ្រោះ (៣៦%)។ ប្រហែលជា ៣៥% យល់ឃើញថា ការរើសអើង បានធ្លាក់ចុះ ប៉ុន្តែប្រមាណ២០%ប៉ុណ្ណោះអះអាងថា តម្រូវការរបស់អ្នកនៅរស់រានមានជីវិត ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីពិការភាព។ ការរីកចំរើនតិចតួចបំផុតត្រូវបានសង្កេតក្នុងការអនុវត្តច្បាប់និងគោលនយោបាយផ្សេងៗដែលផ្តល់ប្រយោជន៍ដល់អ្នកនៅរស់រានមានជីវិត(១៣%)។

ច្បាប់ស្តីពីពិការភាពខុសគ្នារវាងអង្គភាពជាច្រើន ដែលស្ថិតក្នុងស្រុករដ្ឋបាលស្វ័យត Brčko និងពេលខ្លះរវាងតំបន់ និងតំបន់ ប៉ុន្តែការខ្វះចន្លោះកើតមាននៅគ្រប់ទីកន្លែង។ ទោះបីជារបាយការណ៍ពី BiH រាយការណ៍ថាច្បាប់ដែលមានស្រាប់ ត្រូវបាន "អនុវត្តពេញលេញ"[២៨] យ៉ាងណាក៏ដោយ នេះគឺមិនមែនជាការពិតទេពីព្រោះរបាយការជាច្រើនពាក់ព័ន្ធនឹងការរើសអើងក្នុងវិស័យការងារការអប់រំ លទ្ធភាពទទួលបានសេវាគាំពារសុខភាពនិងសេវាកម្មផ្សេងៗទៀតនៅបន្តមាន។ ច្បាប់ស្តីពីការសម្រួលដល់ការចេញចូលនៅតាមទីសាធារណៈមិនត្រូវបានអនុវត្ត ចំណែការរើសអើងរវាងមន្ត្រីស៊ីវិលនិងអ្នកនៅរស់រានមានជីវិតជាយោធា នៅបន្តកើតមាន[២៩] ហើយនៅក្នុងអង្គភាពខ្លះ ច្បាប់ការងារមិនទាន់ទាំងបានអនុម័តផង។[៣០]

មិនមានរដ្ឋាភិបាល ឬអ្នកតំណាងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីន BiH ណាម្នាក់ឆ្លើយតបចំពោះសំណើររបស់យើង ដែលស្នើឱ្យ

មានការឆ្លើយតបចំពោះលទ្ធផលការសិក្សាលើកដំបូងពីបញ្ជីសំណួររបស់អ្នកនៅរស់រានមានជីវិត។

## ការសម្រេចបានលើដំណើរការជួយជនរងគ្រោះ

| ឆ្នាំ | ទម្រង់ J និយាយពីការជួយដល់ជនរងគ្រោះ | សេចក្តីថ្លែងការណ៍នៅ ឯកិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍ស្តីពីការជួយជនរងគ្រោះ | សេចក្តីថ្លែងការណ៍នៅឯកិច្ចប្រជុំរដ្ឋភាគីស្តីពីការជួយជនរងគ្រោះ | អ្នកជំនាញផ្នែកជំនួយជនរងគ្រោះ | អ្នករស់រានជីវិតពីមីនជាគណៈប្រតិភូ |
|---|---|---|---|---|---|
| ២០០៥ | មាន | មាន | មាន | មាន | គ្មាន |
| ២០០៦ | មាន | គ្មាន | មាន | មាន | គ្មាន |
| ២០០៧ | មាន | មាន | មាន | មាន | គ្មាន |
| ២០០៨ | មាន | គ្មាន | មាន | មាន | គ្មាន |
| ២០០៩ | មាន | គ្មាន | មិនដឹង | គ្មាន | គ្មាន |

BiH ពឹងផ្អែកជាសំខាន់ទៅលើអង្គការមិនមែន រដ្ឋាភិបាល និងការគាំទ្រពីអន្តរជាតិ ចំពោះការអនុវត្តជំនួយជនរងគ្រោះ។ (BiH) មិនទាន់បានចាប់ផ្តើមថាតើខ្លួនត្រូវប្រើប្រាស់តួនាទីយ៉ាងម៉េច ក្នុងនាមជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន២៦ ដែលមានចំនួនអ្នកនៅរស់រានមានជីវិតពីគ្រាប់មីនច្រើនជាងគេ និងដែលមានភារកិច្ចធ្ងន់ធ្ងរជាគេ ប៉ុន្តែក៏មានតម្រូវការ និងការរំពឹងទុកដ៏ធំបំផុតផងដែរចំពោះជំនួយចន្លោះឆ្នាំ២០០៥-២០០៩។ សមត្ថភាពជំនួយជងរងគ្រោះនៅក្នុង BiH ត្រូវបានរាយការណ៍ថាសមស្របនៅក្នុងឆ្នាំ២០០៥ ជាពិសេសនៅក្នុងជំនាញគាំពារផ្នែកវេជ្ជសាស្ត្រ និងការស្តារកាយសម្បទា ចំណែកឯការចាប់កំណើតនៃយន្តការប្រតិបត្តិ គឺស្ថិតនៅចំកន្លែងវិស័យផ្សេងៗ ដូចជាវិស័យគាំទ្រចិត្តសង្គមជាដើម។ ទោះជាយ៉ាងណាក៏ដោយ BiH ទំនងជាមិនបានចូលរួមកំលាំងជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលបង្កើតបានយ៉ាងល្អ ដើម្បីទាញផលប្រយោជន៍ពីការចាប់អារម្មណ៍របស់អន្តរជាតិដែលនៅតែមានឥទ្ធពល ដើម្បីធ្វើឱ្យប្រសើឡើងថែមទៀតដល់សេវាកម្មទាំងនេះ ឬដើម្បីដោះស្រាយបញ្ហារ៉ាំរ៉ៃនៃការបញ្ចូលសេដ្ឋកិច្ច និងការអនុវត្តសិទ្ធិ។

BiH ពឹងផ្អែកជាសំខាន់ទៅលើអង្គការមិនមែនរដ្ឋាភិបាល និងការគាំទ្រពីអន្តរជាតិ ចំពោះការអនុវត្តជំនួយជនរងគ្រោះ។ BiH មិនទាន់បានចាប់ផ្តើមថាតើខ្លួនត្រូវប្រើប្រាស់តួនាទីយ៉ាងម៉េចក្នុងនាមជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន២៦ ដែលមានចំនួនអ្នកនៅរស់រានមានជីវិតពីគ្រាប់មីនច្រើនជាងគេ និងដែលមានភារកិច្ចធ្ងន់ធ្ងរជាគេ ប៉ុន្តែក៏មានតម្រូវការ និងការរំពឹងទុកដ៏ធំបំផុតផងដែរចំពោះជំនួយចន្លោះឆ្នាំ២០០៥-២០០៩។ សមត្ថភាពជំនួយជងរងគ្រោះនៅក្នុង BiH ត្រូវបានរាយការណ៍ថាសមស្របនៅក្នុងឆ្នាំ២០០៥ ជាពិសេសនៅក្នុងជំនាញគាំពារផ្នែកវេជ្ជសាស្ត្រ និងការស្តារកាយសម្បទា ចំណែកឯការចាប់កំណើតនៃយន្តការប្រតិបត្តិ គឺស្ថិតនៅចំកន្លែងវិស័យផ្សេងៗ ដូចជាវិស័យគាំទ្រចិត្តសង្គមជាដើម។ ទោះជាយ៉ាងណាក៏ដោយ BiH ទំនងជាមិនបានចូលរួមកំលាំងជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលបង្កើតបានយ៉ាងល្អ ដើម្បីទាញផលប្រយោជន៍ពីការចាប់អារម្មណ៍របស់អន្តរជាតិដែលនៅតែមានឥទ្ធពល ដើម្បីធ្វើឱ្យប្រសើឡើងថែមទៀតដល់សេវាកម្មទាំងនេះ ឬដើម្បីដោះស្រាយបញ្ហារ៉ាំរ៉ៃនៃការបញ្ចូលសេដ្ឋកិច្ច និងការអនុវត្តសិទ្ធិ។

ក្នុងឆ្នាំ២០០៥ BiH បង្ហាញពីគោលបំណងរបស់ខ្លួនសម្រាប់ឆ្នាំ២០០៥-២០០៩ ថាជាផ្នែកនៃឆន្ទះរបស់ខ្លួនចំពោះផែនការសកម្មភាពនៃរ៉ូបឺ ប៉ុន្តែគោលបំណងនោះ មិនត្រូវបានរៀបចំតាមលក្ខណៈ(ឆ្លាត) SMART នោះទេ។ យុទ្ធសាស្ត្រវងនៃជំនួយជនរងគ្រោះរបស់ផែនការសកម្មភាពមីនមានគោលដៅរួមស្រដៀងគ្នា ដែលភាគច្រើនផ្តោតទៅលើការសម្របសម្រួលការគ្រប់គ្រង និងការអភិវឌ្ឍយុទ្ធសាស្ត្របន្ថែម។ ផែនទីផ្លូវដ៏ច្បាស់លាស់សម្រាប់អនុវត្តគោលដៅនេះ មិនត្រូវបានបង្កើត ចំណែកការទទួលខុសត្រូវច្បាស់លាស់ផ្សេងៗ ក៏មិនត្រូវបានកំណត់ចំពោះអ្នកពាក់ព័ន្ធដ៏ទៃទៀតផងដែរ។

ដូចនេះ មានគោលដៅច្បាស់លាស់មួយចំនួនដើម្បីត្រួតពិនិត្យ។ គោលដៅមួយដែលសំដៅដល់ការធ្វើឱ្យប្រសើឡើងដល់ការឆ្លើយតបចំពោះសេវាសង្គ្រោះបន្ទាន់ ត្រូវបានសម្រេចដោយមិនពាក់ព័ន្ធជាមួយដំណើរការជំនួយជងរងគ្រោះ។ គោលដៅដ៏ច្បាស់លាស់បំផុត ដែលសំដៅដល់

សុខុដុមភាវូបនីយកម្មនៃទិន្នន័យជនរងគ្រោះ មិនបានបញ្ចប់ទេរហូតដល់ខែសីហា ឆ្នាំ២០០៩ ដែលបណ្តាលឱ្យមានទិន្នន័យលំអៀងចំពោះគោលបំណងនៃការធ្វើផែនការ។ ចម្លើយតបរបស់អ្នកនៅរស់រានមានជីវិត បានគូសបញ្ជាក់យ៉ាងច្បាស់ថា គោលដៅផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រ និងការស្តារកាយសម្បទាដល់ "គ្រប់អ្នកនៅរស់រានមានជីវិតពីគ្រាប់មីន" ដើម្បីសម្របសម្រួល ការបញ្ចូលផ្នែកសេដ្ឋកិច្ច និងដើម្បីអនុវត្តច្បាប់ ដែលមានស្រាប់ មិនទាន់បានសម្រេចនៅឡើយទេ។[៣១] នៅឯថ្នាក់អន្តរជាតិ សេចក្តីថ្លែងការណ៍ដែលរៀបចំដោយ BiH ជារឿយៗរាយការណ៍ច្រំដែលអំពីសមត្ថភាពចំកន្លែងចាប់តាំងពីឆ្នាំ២០០៥ ជាពិសេសទាក់ទងនឹងបណ្តាញស្តារលទ្ធភាពពលកម្មផ្នែកលើសហគមន៍ដែលមានស្រាប់ និងហេដ្ឋារចនាសម្ព័ន្ធគាំពារសុខភាពទូទៅ។

ខណៈដែលមជ្ឈមណ្ឌលសកម្មភាពកំចាត់មីន BiH ត្រូវបានកំណត់ដើម្បីសម្របសម្រួលជំនួយជនរងគ្រោះនៅក្នុងឆ្នាំ២០០៤ វាមិនមានអាណត្តិច្បាស់លាស់ដើម្បីគ្រប់គ្រងការអនុវត្ត ឬដើម្បីទទួលខុសត្រូវរួមចំពោះស្ថានភាពជំនួយជនរងគ្រោះ។ កិច្ចខិតខំប្រឹងប្រែងជំនួយជនរងគ្រោះរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីន BiH ភាគច្រើនមានការរៀបចំកិច្ចប្រជុំសម្របសម្រួល។ BiH ជាញឹកញាប់រាយការណ៍ច្រំដែលក្នុងសេចក្តីថ្លែងការណ៍ថា ការសម្របសម្រួលអន្តរក្រសួងចាំបាច់ត្រូវមាន។[៣២] ការសម្របសម្រួល ក៏ត្រូវមានផងដែរនៅក្នុងរង្វង់អង្គភាព ដែលនីមួយៗមានប្រធានផ្ទាល់របស់ខ្លួន មានរដ្ឋាភិបាលផ្ទាល់ និងប្រព័ន្ធគាំពារសុខភាព និងសង្គម ព្រមទាំងស្រុករដ្ឋបាលស្វ័យត Brčko។ មកដល់ពាក់កណ្តាលផ្លូវក្នុងរង្វង់ប្រាំឆ្នាំក្នុងឆ្នាំ២០០៧ BiH បានរៀបចំសិក្ខាសាលាថ្នាក់ជាតិចំនួនពីរស្តីពីជំនួយជនរងគ្រោះ ដែលក្នុងនោះ តំណាងមកពីរដ្ឋាភិបាល អង្គការ និងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីន BiHបានចូលរួម។ ទោះបីជាកិច្ចប្រជុំទាំងនេះ មានគោលបំណងពិនិត្យមើលឡើងវិញនូវ និងកែតម្រូវគោលបំណងជំនួយជនរងគ្រោះរបស់ BiH និងកំណត់ការទទួលខុសត្រូវចំពោះការអនុវត្តក៏ដោយ ទាំងនេះមិនធ្លាប់បានសម្រេចទេ។ ផ្ទុយមកវិញ លទ្ធផលនៃដំណើរនេះ ត្រូវបានផ្ទេរសម្រាប់ដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ ដែលគ្របដណ្តប់ពេញមួយទសវត្សផ្សេងទៀត ២០០៩-២០១៩។[៣៣] ផែនការនេះ មិនត្រូវបានអនុម័តយល់ព្រមទេរហូតដល់ខែសីហា ឆ្នាំ២០០៩។ តិចជាង១/៣នៃអ្នកផ្តល់ចម្លើយ (៣០%) គិតថា ដោយសារភាពប្រសើឡើងក្នុងការសម្របសម្រួល ពួកគេបានទទួលសេវាកម្មនៅក្នុងឆ្នាំ២០០៩ច្រើនជាងក្នុងឆ្នាំ២០០៥។

ការខ្វះខាតការទទួលខុសត្រូវចំពោះជំនួយជនរងគ្រោះ និងភាពអសកម្មពីមុនៗមក ឆ្លុះបញ្ចាំងនៅក្នុងចម្លើយតបរបស់អ្នកនៅរស់រានមានជីវិត។ លើសពីនេះទៀត មានតែ៣៩%ប៉ុណ្ណោះជឿថា ពួកគេដឹងថានរណាទទួលខុសត្រូវសម្របសម្រួលជំនួយជនរងគ្រោះ ហើយចំនួនដដែលនេះ និយាយទៀតថា មានការខ្វះចន្លោះផ្នែកសេវាកម្មតិចជាងមុនដោយសារកិច្ចខិតខំសម្របសម្រួល។ អ្នកផ្តល់ចម្លើយភាគច្រើន មានអារម្មណ៍ថាអ្នកនៅរស់រានមានជីវិតត្រូវបានផាត់ចេញពីដំណើរការការធ្វើផែនការជំនួយជនរងគ្រោះ ដោយមានតែ១៥%ប៉ុណ្ណោះជឿថា អ្នកនៅរស់រានមានជីវិតត្រូវបានដាក់បញ្ចូលទៅក្នុងការបង្កើតផែនការសកម្មភាពជាតិ និងក្នុងកិច្ចប្រជុំសម្របសម្រួល ឬតម្រូវការរបស់ពួកគេ ត្រូវបានយកមកពិចារណាពេលរៀបចំធ្វើផែនការ។ ប្រមាណ៩%រាយការណ៍ថា រដ្ឋាភិបាលបានចូលរួមយ៉ាងខ្លាំងក្លាក្នុងការសម្របសម្រួលជំនួយជនរងគ្រោះ ឬថាអ្នកនៅរស់រានមានជីវិត បានទទួលព័ត៌មានទៀងទាត់អំពីសមិទ្ធផលជំនួយជនរងគ្រោះ។ មានតែ៤%ប៉ុណ្ណោះយល់ឃើញថា មានថវិកាពីរដ្ឋាភិបាលច្រើនជាងមុនសម្រាប់ជំនួយជនរងគ្រោះ។ អ្នកនៅរស់រានមានជីវិតពី BiH ជាញឹកញាប់បានចូលរួមក្នុងកិច្ចប្រជុំសិទ្ធិសញ្ញាប្រឆាំងនឹងគ្រាប់មីន ដែលជាទូទៅជាផ្នែកមួយនៃគណៈប្រតិភូពីសង្គមស៊ីវិល។

## សេចក្តីសន្និដ្ឋាន

- សកម្មភាពជំនួយជងរងគ្រោះ ត្រូវបានអនុវត្តដោយគ្មានទាញប្រយោជន៍ពីស្ថានភាពរបស់ BiH ដែលជាប្រទេសមួយក្នុងចំណោមប្រទេស២៦ ដែលមានចំនួនអ្នកនៅរស់រានមានជីវិតពីគ្រាប់មីនច្រើនជាងគេ និងដែលមានភារកិច្ចទទួលខុសត្រូវធ្ងន់ធ្ងរជាគេ តែក៏មានតម្រូវការ និងការរំពឹងទុកដ៏ធំបំផុតផងដែរចំពោះជំនួយ។
- រចនាសម្ព័ន្ធរដ្ឋសាំញ៉ាំបានពន្យាពេលដល់វឌ្ឍនភាពជំនួយជនរងគ្រោះប៉ុន្តែមិនអាចចាត់ទុកថាជាកត្តាសំខាន់ក្នុងការធ្វើឱ្យរាំងស្ទះការរីកចំរើន។

- ការពេញចិត្តពេញថ្លើមនៃអ្នកនៅរស់រានមានជីវិត គឺមានខ្ពស់បំផុតក្នុងវិស័យនានា ដែលនៅទីនោះប្រព័ន្ធជាច្រើនបានប្រតិបត្តិយ៉ាងត្រឹមត្រូវមុន ឆ្នាំ២០០៥ ហើយដែលការរីកចំរើនមួយចំនួនបន្ថែមទៀត ត្រូវបានធ្វើឡើង។
- អង្គការជាច្រើន នៅតែមាននាទីជាអ្នកផ្តល់ដ៏សំខាន់ផ្នែកសេវាកម្មគាំទ្រចិត្តសាស្ត្រ និងសេដ្ឋកិច្ច។
- BiH ខ្វះឆន្ទៈនយោបាយដើម្បីសម្របសម្រួលជំនួយជនរងគ្រោះ ជាក់លាក់ណាមួយនិងដើម្បីកំណត់ការទទួលខុសត្រូវ ដែលបណ្តាលឱ្យមានការពន្យាពេលនៃការធ្វើផែនការជំនួយជនរងគ្រោះ និងសកម្មភាពផ្សេងនៅទសវត្សក្រោយ។
- សេវាកម្ម និងផលប្រយោជន៍ចំពោះជនពិការជាយោធិន មានភាពល្អប្រសើជាងមន្ត្រីស៊ីវិល ប៉ុន្តែទាំងពីរនេះ សុទ្ធតែមានចន្លោះខ្វះខាត។

## ការស្នើរឡើងសម្រាប់ផែនការអនាគត

នៅពេលសួរថាតើពួកគេគិតថាស្ថានភាពរបស់ពួកគេនឹងទៅជាដូចម្តេចក្នុងរយៈពេលប្រាំឆ្នាំក្រោយ ៥៤%នៃអ្នកផ្តល់ចម្លើយបានឆ្លើយតបថា វានឹងប្រែក្លាយទៅជាអាក្រក់ជាងនេះ ២៤%គិតថាវានឹងស្ថិតនៅដដែល និង២២%គិតថា វានឹងមានភាពប្រសើរជាងមុន។ ដើម្បីជួយឱ្យមានអនាគតល្អជាងនេះនៅពេលខាងមុខ សំណូមពរមួយចំនួន អាចយកមកពិចារណា ដូចមានរៀបរាប់ខាងក្រោមៈ

- ចាប់ផ្តើមអនុវត្តភ្លាមៗនូវយុទ្ធសាស្ត្រជំនួយជនរងគ្រោះ (២០០៩-២០១៩) ដែលបង្កើតរួច ដោយប្រើប្រាស់តួនាទីរបស់ BiH ជាប្រទេសមួយក្នុងចំណោមប្រទេសជួយជនរងគ្រោះទាំង២៦ (VA26) ដើម្បីលើកកម្ពស់ព័ត៌មានពីជំនួយជនរងគ្រោះ និងដើម្បីកំណត់គោលដៅជាក់លាក់សម្រាប់ការរីកចំរើន។
- បង្កើតគោលបំណងសម្របសម្រួលដែលមានលក្ខណៈ SMART ដែលសំដៅបង្កើននូវលទ្ធភាព និងការអនុវត្តសេវាកម្ម ដែលអាចសម្រេចបាននៅទូទាំងអង្គភាពផ្សេងៗដែលពាក់ព័ន្ធ។




- ធ្វើឱ្យប្រសើរឡើងដល់ការសម្របសម្រួល ដោយមានក្រុមស្នូលដែលមានអាណត្តិច្បាស់លាស់ និងមានជំនាញដែលប្រតិបត្តិគ្រប់ ផ្នែក និងមានលក្ខណៈបញ្ចូលគ្នារវាងតំបន់រដ្ឋបាលផ្សេងៗគ្នារបស់ BiH។
- អនុវត្តច្បាប់ និងបង្កើនទំនាក់ទំនងរវាងជំនួយជនរងគ្រោះ និង វិស័យពិការភាព។
- ណែនាំ និងអនុវត្តបទដ្ឋានគ្រឹះចំពោះការស្តារកាយសម្បទា និង ការគាំពារសុខភាពក្នុងកំរិតអប្បរមា (ដោយរួមបញ្ចូលឧបករណ៍ផ្សេងៗ) និងការ គាំទ្រផ្នែកចិត្តសង្គម។
- បង្កើនសកម្មភាពដែលមានបញ្ចូលផ្នែកសេដ្ឋកិច្ច ដែលកំណត់ជាក់លាក់ចំពោះជំនួយជនរងគ្រោះ និងបង្កើនលទ្ធភាពអាស្រ័យផល របស់អ្នកនៅរស់រានមានជីវិតចំពោះកម្មវិធីអភិវឌ្ឍផ្សេងៗ។

**សំដីជនរងគ្រោះផ្ទាល់...**

អ្នកផ្តល់ចម្លើយរៀបរាប់ពីខ្លួនគេថាជា : សេរីភាព ទំនាក់ទំនង រួមបញ្ចូល (១០) ភ័យអរ មិនសូវបើកចិត្តឱ្យទូលាយ តាំងចិត្ត បំពេញចិត្ត និងសុទិដ្ឋិនិយម

**សំដីជនរងគ្រោះផ្ទាល់...**

អាទិភាពសម្រាប់ជំនួយសង្គ្រោះ សម្រាប់រយៈពេលប្រាំឆ្នាំបន្ទាប់ :

- លើកកម្ពស់ការស្តារលទ្ធភាពពលកម្ម/ការគាំពារសុខភាព
- ការព្យាបាលដោយ Spa
- ឥតគិតថ្លៃឧបករណ៍ទ្រទ្រង់រាងកាយសប្បនិម្មិត
- គាំទ្រពីអ្នកដែលប្រហាក់ប្រហែលគ្នា
- ជួយរកការងារធ្វើ និងធ្វើការងារដោយខ្លួនឯង
- បង្កើតគំរោងជួយដល់ជនពិការ
- ការអប់រំ
- ការសម្រេចបាននូវសិទ្ធិ
- ការចូលរួមបន្ថែមពីអង្គការដើម្បីស្វែងយល់ពីគោលបំណង
- រដ្ឋាភិបាលយកចិត្តទុកដាក់ច្រើនជាងមុនចំពោះជនពិការ
- ការសម្រួលការចេញចូលកន្លែងសាធារណៈ
- បញ្ហាទីជំរក

**សំដីជនរងគ្រោះផ្ទាល់...**

ប្រសិនបើប្រទេសទាំងឡាយពិតជាយកចិត្តទុកដាក់ដល់អ្នកនៅរស់រានមានជីវិត មែននោះ ពួកគេគួរតែ :

- អនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពជាងមុន
- ផ្តល់ថវិកាបន្ថែមសម្រាប់ជាជំនួយ
- ជួយជនពិការនៅគ្រប់ទិដ្ឋភាពនៃជីវិត ពិសេសអប់រំ និងការងារ
- អនុម័តច្បាប់ដែលមានគុណភាព និងផ្តល់ការគាំទ្រដើម្បីផ្តល់ការងារដល់ជនពិការ
- សម្របសម្រួលរវាងអង្គការ និងរដ្ឋាភិបាល
- បង្កើតកម្មវិធីសម្រាប់ជនពិការ ដែលនឹងបម្រើដល់តម្រូវការរបស់ ពួកគេ និងបញ្ចូលអង្គការដែលតំណាងពួកគេ
- អនុវត្តច្បាប់ឱ្យបានពេញលេញ ពិសេសអប់រំ ការងារ និងការសម្រួលការចេញចូលតាមទីសាធារណៈ
- ជួយយើងបន្ថែម ប៉ុន្តែយើងមិនមែនជាឧបសគ្គ
- បញ្ចូលអ្នកនៅរស់រានមានជីវិតក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងពួកគេ
- ហាមប្រាមនូវរាល់ការរើសអើងយរលើមូលដ្ឋាននៃពិការភាព
- បង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាព
- ដោះស្រាយសិទ្ធិជនពិការនិងធ្វើឱ្យមានសុខដុមដល់ច្បាប់តាមបទដ្ឋានពិភពលោក
- កាត់បន្ថយការយកចិត្តទុកដាក់ចំពោះការិយាធិបតេយ្យ ប៉ុន្តែយកចិត្តទុកដាក់ចំពោះការដាក់បញ្ចូលអ្នកនៅរស់រានមានជីវិត
- ចុះហត្ថលេខា ផ្តល់សច្ចាប័ននិងអនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ

## សំដីជនរងគ្រោះផ្ទាល់ ...

គំនិតដែលមានលំដាប់ផ្សេងៗគ្នា ត្រូវបានសំដែងនៅក្នុងចម្លើយការស្ទង់មតិ និង អ្នកផ្តល់ចម្លើយខ្លះ ត្រូវបានជ្រើសដើម្បីបញ្ចូលយោបល់អំពីសេវាកម្ម ដូចជា :

បុរសម្នាក់ ដែលកំបុតជើងទាំងសងខាងត្រឹមជង្គង់បន្ទាប់ពីគ្រោះថ្នាក់មីន មួយកាលពី១៥ឆ្នាំមុន បានធ្វើការមុនពេលជួបហេតុការណ៍នេះ ប៉ុន្តែបច្ចុប្បន្ននេះ គាត់អត់មានការងារធ្វើទេ។ គាត់និយាយថា : *"គេមិនដែលសួរយើងថាតើយើងត្រូវការអ្វី នៅពេលដែលមកដល់កន្លែងព្យាបាលផ្នែកវេជ្ជសាស្ត្រ ... មិនមានឱកាសការងារ សម្រាប់ប្រភេទពិការភាពរបស់ខ្ញុំទេ"* ។

បុរសម្នាក់ផ្សេងទៀត បានទទួលរងរបួសនៅក្នុងឧប្បត្តិហេតុផ្ទុះមីន កាលពី ១៧ឆ្នាំមុន ដែលបណ្តាលឱ្យគាត់ដាច់ជើងខាងស្តាំរបស់គាត់ និងរបួសសួតបាននិយាយថា : *"សេវាកម្មព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការផលិតឧបករណ៍ទ្រទ្រង់រាងកាយសប្បនិម្មិតមានភាពប្រសើរឡើង"* ។

បុរសរៀបការរួចម្នាក់ ដែលធ្លាប់ជាទាហ៊ាននៅពេលជួបឧប្បត្តិហេតុបច្ចុប្បន្ន កំពុងរស់នៅក្នុងភូមិមួយ និងកំពុងរកប្រាក់ចំណូលតាមរយៈកាប់ឈើឱ្យគេជឿថា: *" អនាគតនឹងល្អជាងនេះ (ភាពប្រសើរឡើងគឺ) ដោយសារការពិតដែលថា រដ្ឋាភិបាល អនុម័តច្បាប់អំពីសិទ្ធិទាហ៊ានជាកសិករ និងជនពិការ ដើម្បីទទួលបានសេវាស្តារលទ្ធភាពពលកម្ម"*។

ស្ត្រីវ័យចំណាស់អាយុ៤០ឆ្នាំ ដែលមិនធ្លាប់មានឱកាសទទួលបានការអប់រំហួស ពីបឋមសិក្សា ដោយសារស្ថានភាពហិរញ្ញវត្ថុ បានថ្លែងចំណាប់អារម្មណ៍ថា : *"រដ្ឋាភិបាល និងនិយោជក មិនបានយកចិត្តទុកដាក់គ្រប់គ្រាន់ចំពោះការងាររបស់អ្នកនៅរស់រានមាន ជីវិតពីគ្រាប់មីន និងជនពិការទូទៅ"* ។

បុរសម្នាក់ដែលលៃលកករក្សាការងារ របស់គាត់ជាជាងជួសជុលគ្រឿងម៉ាស៊ីន ចាប់តាំងពីមុនមាន ឧប្បត្តិហេតុផ្ទុះគ្រាប់មីនបានកត់សំគាល់ថា : *"រដ្ឋាភិបាលបានអនុម័ត ច្បាប់ ប៉ុន្តែច្បាប់ទាំងនោះមិនបានផ្តល់លទ្ធផលដូចក្តីរំពឹងទុក"*។

## Bosnia-Herzegovina

[1] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 170.

[2] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 174. Other figures provided by BiH differ slightly, but contamination is still more than twice the estimated area contaminated in Afghanistan.

[3] UNDP, "2008 Statistical Update − Bosnia and Herzegovina," http://hdrstats.undp.org/en/countries/data_sheets/cty_ds_BIH.html, accessed 11 July 2009; and UNDP, *Human Development Report 2004: Cultural Liberty in Today's Diverse World*, New York, 2004, p.140.

[4] World Bank, "Gross national income per capita 2008, Atlas method and PPP," 1 July 2009, http://siteresources.worldbank.org/DATASTATISTICS/Resources/GNIPC.pdf; and UN Statistics Division, "Per capita GNI at current prices – US Dollars," http://data.un.org/Data.aspx?d=SNAAMA&f=grID%3A103%3BcurrID%3AUSD%3BpcFlag%3A1, accessed 11 July 2009.

[5] CIA, *The World Factbook – Bosnia and Herzegovina*, 2008, https://www.cia.gov/library/publications/the-world-factbook/geos/BK.html; and 2004, http://www.umsl.edu/services/govdocs/wofact2004/geos/bk.html, accessed 11 July 2009.

[6] WHO, "Detailed Database Search: Bosnia and Herzegovina,"http://apps.who.int/whosis/data/Search.jsp?indicators=%5bIndicator%5d.%5bHSR%5d.Members, accessed 11 July 2009.

[7] WHO, "World Health Statistics 2009," Geneva, 2009, pp. 95-96. The WHO estimates that countries with less than 23 healthcare professionals (physicians, nurses and midwives) per 10,000 population are unlikely to achieve adequate coverage.

[8] UN, "Convention [on the Rights of Persons with Disabilities] & Optional Protocol Signatories & Ratification," http://www.un.org/disabilities/countries.asp?id=166, as accessed on 1 August 2009; delays in updating the webpage were noted.

[9] UNDP-BiH, "Eradicate extreme poverty and hunger," 11 February 2009, http://www.undp.ba/index.aspx?PID=32&RID=1; UNDP, "2008 Statistical Update − Bosnia and Herzegovina," http://hdrstats.undp.org/en/countries/data_sheets/cty_ds_BIH.html; and CIA, *The World Factbook – Bosnia and Herzegovina*, 2008, https://www.cia.gov/library/publications/the-world-factbook/geos/BK.html, accessed 11 July 2009.

[10] "Final Report of the Sixth Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, p. 111. The situation was no clearer in 2009 due to ongoing work in creating a unified national database.

[11] Bosnia and Herzegovina is divided into two political divisions called entities: the Bosniak-Croat Federation of Bosnia and Herzegovina and the Republika Srpska. Each entity has its own government, parliament, and health and social systems.

[12] 7% non-response rate.

[13] BHMAC, "Mine victims: Bosnia and Herzegovina, 10 April 2009," (translation) http://www.bhmac.org/ba/filedownload.daenet?did=474, 10 May 2009.

[14] No questionnaire responses have been received from VA/disability practitioners in Bosnia and Herzegovina.

[15] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 182.

[16] ICBL, *Landmine Monitor Report 2007*, Ottawa, October 2007, p. 195.

[17] 2% non-response rate.

[18] "Final Report of the Sixth Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, pp. 114-115.

[19] Statement of BiH, Seventh Meeting of States Parties, Geneva 19 September 2006; and statement of BiH, Eighth Meeting of States Parties, Dead Sea, 21 November 2007.

[20] ICBL, *Landmine Monitor Report 2006*, Ottawa, July 2006, p. 226.

[21] "Final Report of the Sixth Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005,p. 114.

[22] 7 % was not sure.

[23] ICBL, *Landmine Monitor Report 2002*, Washington, DC, August 2002, p.126.

[24] ICBL, *Landmine Monitor Report 1999*, Washington, DC, April 1999, p. 567.

[25] Statement of BiH, Eighth Meeting of States Parties, Dead Sea, 21 November 2007.

[26] Article 7 Report, Form J, 2005, 2006, 2007 and 2008; and statement of BiH, Ninth Meeting of States Parties, Geneva, 28 November 2009.

[27] 5% non-response rate.

[28] "Final Report of the Sixth Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, p. 119.

[29] US Department of State, "2008 Country Reports on Human Rights Practices: Bosnia and Herzegovina," Washington, DC, 25 February 2009; and email from Radojka Kela, Chief of Department for Normative and Legal Business, Ministry of Labour and Protection of Veterans and Disabled Persons of RS, Banja Luka, 5 May 2009.

[30] Statement of BiH, Ninth Meeting of States Parties, Geneva, 28 November 2009.

[31] "Final Report of the Sixth Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, pp. 114-117.

[32] BiH did organize cross entity representation from the health ministries at Mine Ban Treaty meetings, which could have been a positive first step.

[33] Co-Chairs of the Standing Committee on Victim Assistance and Socio-Economic Reintegration, "Status of Victim Assistance in the Context of the AP Mine Ban Convention in the 26 Relevant States Parties 2005 – 2008," Geneva, 28 November 2008.